00648422

E51/16

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 02 / 2011
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

## ដីកាបង្គាប់ឲ្យមេធាវីការពារ អៀង សារី ដាក់នូវអញ្ញត្រកម្ម

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង ធីរិទ្ធ
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
សា សូវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ។

**បានឃើញ** ការជូនដំណឹងជាមុនរបស់មេធាវីការពារ អៀង សារី ដែលមានបំណងដាក់នូវអញ្ញត្រកម្មចំនួន០៨ (ប្រាំបី) ដែលមាន ១១១ ទំព័រ (ជាភាសាអង់គ្លេស) និងការបដិសេធរបស់អង្គជំនុំជម្រះអំពីការដាក់អញ្ញត្រកម្មនេះ ដោយមិនបានគោរពតាមការកំណត់នូវចំនួនទំព័រ ដូចដែលមានចែងនៅក្នុងសេចក្តី ណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ។

**បានឃើញផងដែរ** នូវសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ ទាក់ទងនឹងការកំណត់ចំនួនទំព័រសម្រាប់ការដាក់នូវអញ្ញត្រកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឲ្យមេធាវីការពារ អៀង សារី បន្ថែមនូវចំនួនទំព័រ និងពេលវេលា ។

**ហេតុដូច្នេះ**

**បង្គាប់** ឲ្យមេធាវីការពារ អៀង សារី ដាក់នូវអញ្ញត្រកម្មរួម ដោយមិនឲ្យលើសពី ៣៥ ទំព័រ (ជាភាសាអង់គ្លេស) ឬ ៥០ ទំព័រ (ជាភាសាខ្មែរ) ដោយមិនឲ្យលើសពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ។

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9 ។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

**អនុញ្ញាត** ឱ្យមេធាវីការពារ អៀង សារី ដាក់នូវអញ្ញត្រកម្មនេះតែជាភាសាអង់គ្លេស ប្រសិនបើការបកប្រែធ្វើឱ្យមានការយឺតយ៉ាវក្នុងការដាក់នូវឯកសារជាពីរភាសា ប៉ុន្តែត្រូវដាក់នូវឯកសារជាភាសាខ្មែរក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន